ឆ្នាំទី២ លេខ៥

# ព្រឹត្តិប័ត្រព័ត៌មានសមាគមស្វាយចន្ទីកម្ពុជា

Tel: +855-77-629-288/12-600-576 Email: info@cac-camcashew.org https://cac-camcashew.org

## NEWSLETTER

April 2025 - Volume 2 Issue 5



# Mission and Vision of CAC: Shaping the Future of Cambodia's Cashew Industry

**Mission**

To alleviate poverty by empowering cashew farmers and promoting sustainable agricultural practices, in alignment with government policy. CAC aims to strengthen the cashew nut industry's image both nationally and internationally, ensuring its growth and prosperity.

**Vision**

To position Cambodia as a global leader in cashew production and marketing, fostering innovation and sustainability to enhance the livelihoods of local communities and contribute to the national economy.

**Goal**

- Provide technical training to cashew nut farmers and agricultural cooperatives across Cambodia.
- Establish community warehouses in all cashew-producing provinces.
- Launch CAC's first processing factory for processor training.
- Transform Kampong Thom into Cambodia's largest cashew industrial zone.



SILOT OUN
CHAIRPERSON,CAC

# Message from the President

Dear Members, Partners, and Stakeholders,

Reflecting on the first quarter of 2025, our cashew sector has encountered opportunities and challenges, highlighting collaboration and innovation. We remain committed to sustainable growth, resilience, and economic progress.

I commend our farming communities, whose efforts drive our achievements. Special thanks to NGOs, investors, and government entities, whose support greatly advances our initiatives.
This newsletter shares our progress, challenges, and opportunities transparently. Continued cooperation will build a thriving and sustainable future for Cambodia's cashew industry.

Thank you for your ongoing support.

Warmest regards,

Silot UonPresident, Cashew Nut Association of Cambodia (CAC)


ការផ្សាយពីការិយាល័យកណ្តាល សសក

CAC Publication Editorial Committee

**Chief Editor:** Mr. Silot Uon

**Head of admin and Finance:** Mr. Ma Vuthy

**Head of Public Relations NAnd International Affairs:** Mr. Suy KokThean

**Technical Assistant:** Mr. Try Kimsrieng, Mr. Tann Huypheng, Mr. Chhim Vantha

**Graphic Designer:** Mr. Chhim Chhouden, Mr. Kak Ratana



# ២០២៤ កសិកម្មទទួលបានការវិនិយោគតិចជាងគេ

# Agriculture Receives the Least Investment in 2024

By Sirey Muny, BC News

**ខណៈកម្ពុជាឈរលេខរៀងទី៣ នៅអាស៊ានដែលបាននាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិ ការវិនិយោគលើវិស័យកសិកម្មមានចំនួនត្រឹមតែ២%ប៉ុណ្ណោះ ដែលស្មើនឹងទឹកប្រាក់ ១២១លានដុល្លារ អាមេរិក។ ចំនួននេះតិចជាងគេ បើប្រៀបធៀបការវិនិយោគផ្សេងទៀត។**

អាជីវកម្មដែលទទួលបានការវិនិយោគឈរលេខរៀងទី១ គឺវិស័យឧស្សាហកម្ម ដោយអាចទាញទឹកប្រាក់ វិនិយោគបាន ៤,៨ពាន់លានដុល្លារអាមេរិក។ ហើយលុយបោះទុនវិនិយោគដេញតាមពីក្រោយវិស័យ ឧស្សាហកម្ម គឺវិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យទេសចរណ៍។

ឆ្នាំ២០២៤ ការវិនិយោគលើវិស័យកសិកម្មមាន១២១លានដុល្លារអាមេរិក ស្មើនឹង២% នៃការ និយោគសរុបជិត៧ពាន់លានដុល្លារអាមេរិកនេះបើយោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ប៉ុន្តែកម្ពុជាត្រូវចាយអស់ជាង៥៦០លានដុល្លារ លើការនាំចូលជីកសិកម្ម ថ្នាំពុលកសិកម្មនិងថ្នាំស្មៅក្នុង រយៈពេល១១ខែ ឆ្នាំ២០២៤ នេះបើតាមក្រសួងកសិកម្ម។ ការចំណាយនេះលើសចំណូលជាង ៤០០ ភាគរយ៕

While Cambodia ranks third in ASEAN for agricultural product exports to international markets, investments in agriculture account for only 2%, which is equivalent to 121 million US dollars.

This amount is smaller compared to investments in other sectors.

The leading investment is the industrial sector, which has attracted 4.8 billion US dollars in investments. Following the industrial sector, infrastructure and tourism investments also outpace agriculture.

By 2024, investment in agriculture is expected to reach 121 million US dollars, which is equivalent to 2% of the total investment in the sector, amounting to nearly 7 billion US dollars, according to the Council Development of Cambodia.

However, Cambodia has spent over $560 million on imports of agricultural fertilizers, pesticides, and herbicides in the first 11 months of 2024, as reported by the Ministry of Agriculture Forestry and Fisheries. This expenditure exceeds the revenue from agriculture by more than 400%.

# ព័ត៌មាន និងបច្ចុប្បន្នភាព
# NEWS & UPDATES




## គណៈប្រតិភូចិនចុះស្វែងយល់ពីសក្តានុពលផលិតកម្ម ស្វាយចន្ទីនៅក្នុងខេត្តកំពង់ធំ

ម៉ម គន្ធា កាសែតខ្មែរថាមស៍ ១៦ មករា ២០២៥

គណៈប្រតិភូវិនិយោគចិនកាលពីពេលថ្មីៗនេះបាន ធ្វើទស្សនកិច្ចនៅកាន់ខេត្តកំពង់ធំ ដើម្បីស្វែងយល់ពី សក្តានុពលនៃផលិតកម្មស្វាយចន្ទី និងឱកាសសម្រាប់ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មសម្រាប់ការ នាំចេញ គ្រាប់ស្វាយចន្ទីដែលត្រូវបានកែច្នៃទៅកាន់ប្រទេសចិន។ យោងតាមសេចក្ដីប្រកាសរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម កាលពីថ្ងៃសៅរ៍ បានឱ្យដឹងថា លោក ធន់ សុភ័ក្រ្ត អនុប្រធានការិយាល័យកសិ-ពាណិជ្ជកម្ម នៃ នាយកដ្ឋាន កសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានសម្របសម្រួលដំណើរទស្សនកិច្ចរបស់ គណៈប្រតិភូចិនពីទីក្រុង ស៊ីអាន (Xi’an) នៃខេត្តសាន ស៊ី (Shanxi) ទីក្រុងសៀងហៃ ដើម្បីចុះពិនិត្យផលិតកម្ម គ្រាប់ស្វាយចន្ទី ក្នុងខេត្តកំពង់ធំ ចាប់ពីថ្ងៃទី ៨ ដល់ថ្ងៃទី ១០ ខែមករា។ គណៈប្រតិភូចិនបានទៅទស្សនារោងចក្រ កែច្នៃ ស្វាយចន្ទីដែលមានការចូលរួមពីកសិករដាំស្វាយចន្ទី សហគមន៍កសិកម្មទំនើប អ្នកប្រមូលទិញគ្រាប់ ស្វាយចន្ទី និងសមាគមស្វាយចន្ទីកម្ពុជា។



# A CHINESE INVESTMENT DELEGATION RECENTLY VISITED KAMPONG THOM

A Chinese investment delegation recently visited Kampong Thom province to thoroughly evaluate the region's cashew production capabilities and explore potential commercial collaborations, especially regarding the export of processed cashew nuts to the Chinese market.

Thun Sopheak, Deputy Head of the Agribusiness Office at the Department of Agro-Industry, Ministry of Agriculture, Forestry and Fisheries (MAFF), coordinated this important visit. The delegation, representing investors from Xi'an city of Shanxi Province and Shanghai, spent January 8-10 in Kampong Thom to closely inspect cashew production processes, according to a statement released by the Department of Agro-Industry on Saturday.

During the visit, the Chinese delegation toured cashew processing factories and engaged directly with local stakeholders, including cashew farmers, modern farming communities, cashew nut collectors, and representatives of the Cashew Nut Association of Cambodia (CAC). The delegation expressed interest in Cambodia's production potential and discussed avenues to strengthen cooperation and boost economic opportunities for both countries through enhanced cashew trade.

Mom Kunthea / Khmer Times January 16

# កម្ពុជានឹងពង្រីកទីផ្សារនាំចេញផលិតផលស្វាយចន្ទីកម្ពុជា ទៅកាន់អង់គ្លេស និងឥណ្ឌា

BC News ២១ មករា ២០២៥

កម្ពុជាតាមរយៈក្រសួងពាណិជ្ជកម្ម មានគម្រោងនឹងបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅ ទីក្រុងឡុងដ៍ នៃចក្រភពអង់គ្លេស និងទីក្រុងញ៉ូវដែលី នៃសាធារណរដ្ឋឥណ្ឌា ដើម្បីជំរុញការនាំចេញ ផលិតផលស្វាយចន្ទីកម្ពុជា ទៅកាន់ទីផ្សារប្រទេសទាំងពីរនាពេលខាងមុខ។

លោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មមានប្រសាសន៍ថា មជ្ឈមណ្ឌលពាណិជ្ជកម្មនេះ នឹងក្លាយជាច្រកទ្វារ ដ៏សំខាន់ក្នុងការផ្សព្វផ្សាយនិងជំរុញ ផលិតផលខ្មែរទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈការដាក់តាំង បង្ហាញផលិតផល សក្តានុពលកម្ពុជា និងឯកសារពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងវប្បធម៌របស់កម្ពុជា ដើម្បីទាក់ទាញពាណិជ្ជករ វិនិយោគិន និងភ្ញៀវទេសចរបរទេស មកកាន់ព្រះរាជាណាចក្រកម្ពុជាថែមទៀត។



## ដៃគូសហការ / PARTNERSHIP



# CAMBODIA TO EXPAND CASHEW EXPORT MARKETS TO UK AND INDIA

BC News January 21, 2025

**The Ministry of Commerce of Cambodia is preparing to establish the Cambodian Private Trade Center in London, United Kingdom, and New Delhi, India. This initiative's primary objective is to facilitate the export of Cambodian cashew products to these two markets.**

The Minister of Commerce has mentioned that the Trade Center will function as the principal gateway for the promotion of Cambodian products in international markets. This initiative aims to highlight Cambodia's potential products alongside relevant documentation concerning trade, investment, tourism, and culture. The objective is to attract a greater number of business professionals, investors, and foreign tourists to the Kingdom of Cambodia.

In an interview with Buddhist News on January 21, 2025, Mr. Silot Uon, President of the Cashew Nut Association of Cambodia, asserted his strong endorsement of the promotion and expansion of new markets in the UK and India. He firmly believes that this initiative signals a prosperous future for the cashew sector in Cambodia.

Mr. Silot stressed the critical importance of market diversification and unequivocally supports the Ministry of Commerce's efforts to broaden opportunities for selling Cambodian products. This strategic move is essential for the growth and success of the industry.

# សហរដ្ឋអាមេរិក ទិញគ្រាប់ស្វាយចន្ទីវៀតណាម ប្រមាណ ១ពាន់លានដុល្លារ ក្នុងឆ្នាំ ២០២៤

PNN News

សហរដ្ឋអាមេរិក បានទិញគ្រាប់ស្វាយចន្ទី ដែលមានតម្លៃប្រមាណ ១ពាន់ ១រយ
លានដុល្លារអាមេរិកពី ប្រទេសវៀតណាម ក្នុងឆ្នាំ ២០២៤ ហើយតួលេខនេះ
ស្មើនឹង ៩៨% នៃការនាំចូលគ្រាប់ធញ្ញជាតិ ទាំងអស់របស់អាមេរិក។ នេះបើ
យោងតាមការចេញផ្សាយដោយ សារព័ត៌មានក្នុងស្រុកវៀតណាម នៅថ្ងៃនេះ។
សមាគមស្វាយចន្ទីវៀតណាម បានគូសបញ្ជាក់ថា វៀតណាម នាំចេញគ្រាប់ស្វាយ
ចន្ទីជាង ១ពាន់ ១រយលានដុល្លារអាមេរិក ទៅកាន់សហរដ្ឋអាមេរិក ហើយតួលេខ
នេះខ្ពស់ជាងឆ្នាំ ២០២៣ ដល់ទៅ ៣០%។

ក្នុងរយៈពេល ១៨ឆ្នាំជាប់គ្នា វៀតណាម គឺជាអ្នកនាំចេញគ្រាប់ស្វាយចន្ទីកំពូល
ដែលស្មើនឹង ៨០% នៃការនាំចេញទូទាំងពិភពលោក។យោងតាមសមាគម
ស្វាយចន្ទីវៀតណាមបានឱ្យដឹងថា តម្រូវការគ្រាប់ស្វាយចន្ទី កំពុងកើនឡើង
ដោយសារតែការរីកចម្រើនយ៉ាងឆាប់រហ័សនៃឧស្សាហកម្មកែច្នៃម្ហូបអាហារ
នគរូបនីយកម្ម និងការផ្លាស់ប្តូរទម្លាប់អ្នកប្រើប្រាស់។

ប៉ុន្តែវៀតណាម ប្រឈមមុខនឹងបញ្ហាដូចជា ការពឹងផ្អែកលើគ្រាប់ស្វាយចន្ទីឆៅ
ដែលនាំចូល ថ្លៃដើមផលិតកម្មខ្ពស់ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
លើ វិស័យកសិកម្ម។ ទោះបីជាតម្រូវការអាហារ ងាយស្រួលផ្តល់ឱកាសធំក៏ដោយ
ក៏ឧស្សាហកម្មស្វាយចន្ទីរបស់ប្រទេសនេះ ត្រូវផ្តោតលើការធ្វើឱ្យប្រសើរ ឡើងនូវ
បច្ចេកវិទ្យា និងខ្សែច្រវាក់តម្លៃ ដើម្បីបង្កើនការប្រកួតប្រជែងរបស់ខ្លួន។



## ដៃគូសហការ / PARTNERSHIP

# US BUYS ABOUT $ 1 BILLION WORTH OF VIETNAMESE CASHEW NUTS IN 2024

PNN News

In 2024, the United States purchased approximately $1.1 billion worth of cashew nuts from Vietnam, which represents 98% of all US imports of this product. This information was reported by local Vietnamese media today. The Vietnam Cashew Association noted that Vietnam's exports of cashew nuts to the United States increased by 30% compared to 2023.

For 18 consecutive years, Vietnam has established itself as the top exporter of cashew nuts, commanding an impressive 80% of global exports. The Vietnam Cashew Association firmly states that the demand for cashew nuts is surging, driven by the rapid growth of the food processing industry, urbanization, and shifting consumer habits.

Vietnam's cashew industry encounters several significant challenges, particularly its dependence on raw cashew nut imports, which contribute to elevated production costs. Moreover, the effects of climate change pose additional risks to agricultural productivity. Despite the increasing demand for convenient food products, it is imperative for the cashew sector to concentrate on enhancing technology and optimizing value chains to improve its competitiveness in the global market.





# ស.ស.ក បារម្ភថាភ្លៀង អាចទាញទម្លាក់ទិន្នផលស្វាយចន្ទីឆ្នាំនេះ

# CAC CONCERNS YIELD DROP DUE TO WEATHER CONDITION

**សារព័ត៌មាន ថ្មីៗ ១១ មីនា**

ប្រធានសមាគមស្វាយចន្ទីកម្ពុជា លោក អួន ស៊ីឡុត បារម្ភពីការថយចុះទិន្នផលស្វាយចន្ទី បន្ទាប់ពីមានភ្លៀងធ្លាក់ប៉ុន្មានមេ ធ្វើឱ្យផ្កាចន្ទីក្នុងចម្ការរបស់លោកជ្រុះច្រើន។ សសក កំពុងតាមដានយ៉ាងយកចិត្តទុកដាក់លើការប្រែប្រួលអាកាសធាតុ និងបានណែនាំឱ្យកសិករត្រៀមការពារសត្វល្អិត និងជំងឺ។
លោក អួន ស៊ីឡុត បានប្រាប់សារព័ត៌មានឌីជីថលថ្មីៗ នៅថ្ងៃទី១១ ខែមីនានេះថា ការអូសបន្លាយនៃអាកាសធាតុត្រជាក់ក្នុងរដូវប្រាំងឆ្នាំ ២០២៥នេះ បានធ្វើឱ្យចន្ទីគាំងក្តឹប។ បន្ថែមពីលើនោះ បរិមាណទឹកភ្លៀង ក៏កំពុងធ្វើឱ្យផ្កាចន្ទីក្នុងចម្ការរបស់លោកនៅឯខេត្តកំពង់ធំជ្រុះប្រហែល៥០ភាគរយផងដែរ។

ករណីភ្លៀងគ្របដណ្តប់ទូទាំងប្រទេសច្រើនដង ទិន្នផលស្វាយចន្ទីនឹងអាចធ្លាក់ចុះច្រើន។ ប្រសិនបើ រដូវវស្សាចូលមកលឿនក្នុងខែឧសភា ដូចការព្យាកររបស់ក្រសួងធនធានទឹក និងឧតុនិយម ដំណាំចន្ទីធ្លាក់ចុះទិន្នផលចន្លោះពី ១០% ទៅ  ៣០% ហើយគុណភាពគ្រាប់កាន់តែយ៉ាប់យឺន។ នេះជាការព្រួយបារម្ភរបស់លោក អួន ស៊ីឡុត ដោយអះអាងថា សមាគមស្វាយចន្ទីកម្ពុជា កំពុងតាមដានហានិភ័យអាកាសធាតុ ជាមួយកសិករគ្រប់បណ្តាខេត្ត និងបានណែនាំឱ្យពួកគេត្រៀមការពារសត្វល្អិត និងជំងឺ។

លោក ប្រាប់ដូច្នេះថា៖«មានការប៉ះពាល់ច្រើន សូម្បីតែចម្ការខ្ញុំ! ព្រោះថា ភ្លៀងមួយមេធំកាលពីប៉ុន្មានថ្ងៃមុនហ្នឹង បានធ្វើឱ្យជ្រុះផ្កាប្រហែល៥០ភាគរយ។ ហេតុនេះ យើងកំពុងបារម្ភចំពោះការធ្លាក់ចុះទិន្នផល។ ប៉ុន្តែ មកទល់ពេលនេះ នៅមិនទាន់ដឹងថា ភ្លៀងធ្លាក់តែតំបន់ខ្ញុំ (ខេត្តកំពង់ធំ) ឬនៅទូទាំងប្រទេសនៅឡើយទេ។ យ៉ាងណាបើសិន ភ្លៀងទូទាំងប្រទេស ផលនឹងអាចថយចុះច្រើន ដូច្នេះ យើងកំពុងតាមដាន និងសួរនាំកសិករតាមបណ្តាខេត្តផ្សេងទៀត»។

Silot Uon, President of the Cashew Nut Association of Cambodia (CAC), has expressed significant concerns regarding declining cashew yields due to adverse weather, particularly heavy rainfall. In an interview on March 11, Mr. Silot noted that prolonged cold weather during the 2025 dry season severely impacted cashew trees, causing them to freeze. Additionally, excessive rainfall led to an approximate 50% loss of cashew flowers at his plantation in Kampong Thom province, highlighting immediate threats to local production.

CAC continues to closely monitor these climate-related impacts, emphasizing the importance of proactive guidance to farmers. Mr. Silot warned that if widespread rainfall occurs nationwide, as forecasted by the Ministry of Water Resources and Meteorology, cashew yields could significantly decline—potentially by up to 30%—and nut quality would suffer.

Heavy rains foster conditions conducive to pests like tea mosquitoes and caterpillars, causing extensive damage to cashew flowers and young nuts. Increased humidity also heightens the risk of diseases affecting blossoms and fruit, further complicating agricultural challenges.

In response, CAC is advising farmers across the country on effective pest management and disease prevention strategies. Mr. Silot stressed the urgency of addressing these climatic threats to protect Cambodia's cashew production and farmers' livelihoods. Continuous monitoring and farmer engagement remain top priorities for CAC to mitigate adverse weather impacts.

# សហភាពអឺរ៉ុបវិនិយោគទឹកប្រាក់ប្រមាណ៨៧លានដុល្លារអាមេរិកទៅក្នុងវិស័យកសិកម្មនៅកម្ពុជា

**វ៉ាយោអេហ្សអ៊ឹម ១៤ មីនា**

ធនាគារវិនិយោគអឺរ៉ុបសកល(EIB Global) ដែលជាសាខាសកលរបស់ធនាគារវិនិយោគអឺរ៉ុប និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយនាថ្ងៃនេះ ដើម្បីផ្តល់កញ្ចប់ជំនួយឥតសំណងចំនួន១៥លានអឺរ៉ូរបស់សហភាពអឺរ៉ុប សម្រាប់កម្មវិធីគាំទ្រសេដ្ឋកិច្ចជនបទ និងពាណិជ្ជកម្មផលិតផលកសិកម្ម (ASPIRE-AT)។ កម្មវិធី ASPIRE-AT មានគោលដៅធ្វើទំនើបកម្មវិស័យកសិកម្ម លើកកម្ពស់សន្តិសុខស្បៀង និងពង្រឹងសក្តានុពលនៃការនាំចេញ។ ជំនួយនេះនឹងបំពេញបន្ថែមលើឥណទានចំនួន៦០លានអឺរ៉ូ ពីធនាគារវិនិយោគអឺរ៉ុបសកល (EIB Global) និងជំនួយគាំទ្រចំនួន៤,៥លានអឺរ៉ូទៀតពីសហភាពអឺរ៉ុប សម្រាប់ជំនួយបច្ចេកទេសដែលនឹងត្រូវអនុវត្តដោយធនាគារវិនិយោគអឺរ៉ុប (EIB)។ ជំនួយនេះនាំឱ្យទឹកប្រាក់វិនិយោគសរុបដែលគាំទ្រដោយសហភាពអឺរ៉ុបនៅក្នុងកម្មវិធីនេះកើនឡើងដល់ជិត៨០លានអឺរ៉ូ ឬប្រមាណ៨៧លានដុល្លារអាមេរិក។

ការផ្តល់ហិរញ្ញប្បទានរបស់សហភាពអឺរ៉ុបនេះ នឹងជួយដល់ការធ្វើទំនើបកម្មវិស័យកសិកម្មរបស់កម្ពុជា ផ្តល់ជូនកសិករខ្នាតតូច កសិធុរកិច្ច និងក្រុមផលិតនូវឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជំរុញផលិតកម្ម ផ្តល់លទ្ធភាពចូលទៅកាន់ទីផ្សារថ្មីៗ និងលើកកម្ពស់សុវត្ថិភាពចំណីអាហារ។ គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់កសិករខ្នាតតូចចំនួន១០០,០០០នាក់ និងគ្រួសារមានដីធ្លីខ្នាតតូចចំនួន២៥,០០០គ្រួសារ ដោយបង្កើតឱកាសរកចំណូលថ្មីៗ ជាពិសេសនៅតំបន់ជនបទ ដោយផ្តោតជាសំខាន់ទៅលើការផ្តល់ភាពអង់អាចដល់ស្ត្រី បំផុសឱ្យមានការចូលរួមពីយុវជន ក៏ដូចជាផ្តល់ការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិចផងដែរ។




## EU INVESTS ABOUT $ 87 MILLION IN AGRICULTURE IN CAMBODIA

The European Investment Bank (EIB) Global recently formalized a €15 million grant agreement to support rural economic initiatives and agricultural trade through the ASPIRE-AT program in Cambodia. The program aims to modernize agriculture, improve food security, and enhance export capabilities. Alongside this grant, EIB Global approved a €60 million loan and an additional €4.5 million from the European Union (EU) for technical assistance. Collectively, the EU-backed funding in Cambodia's agricultural sector under ASPIRE-AT now totals approximately €80 million (about USD 87 million).

This significant investment will directly impact around 100,000 smallholder farmers and 25,000 smallholder households, creating new income-generating opportunities and driving economic growth, particularly in rural communities. The program prioritizes inclusive development by emphasizing the empowerment of women, the engagement of youth, and targeted support for indigenous communities.

EIB Vice President Nicola Beer emphasized the bank's ongoing commitment to the ASPIRE-AT program, recognizing its vital role in Cambodia's economy and food security. The funding is expected to substantially boost agricultural productivity, increase farmers' incomes, and expand market opportunities for Cambodian agricultural products internationally. Ultimately, this initiative is designed to promote sustainable agricultural growth, alleviate poverty, and enhance living standards for rural Cambodian communities.

# តម្លៃគ្រាប់ស្វាយចន្ទីនៅដើមរដូវឆ្នាំនេះ ខ្ពស់ ចន្លោះពី៦០០០ ទៅ ៦៦០០រៀល ក្នុងមួយគីឡូក្រាម

# FARMERS ENJOY STABLE PRICE OF RCN

Kem Sinath, Oknha News, February 21, 2025

លោក តូច ប៊ុនហួរ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកឡើងថា ស្ថានភាពទីផ្សារ និងតម្លៃគ្រាប់ស្វាយចន្ទីនៅដើមរដូវឆ្នាំនេះ មានតម្លៃខ្ពស់ដូចឆ្នាំ២០២០ ដែលមានតម្លៃចន្លោះពី៦០០០ ទៅ៦ ៦០០រៀល ក្នុងមួយគីឡូក្រាម។ លោកបានលើកឡើងបែបនេះ ក្នុងពេលដឹកនាំក្រុមការងារចុះពិនិត្យស្ថានភាពការងារបង្កបង្កើនផល ជាពិសេសដំណាំឧស្សាហកម្ម ដំណាំស្វាយចន្ទី ទីតាំងឃ្លាំង ស្ថានភាពទីផ្សារ និងតម្លៃ នៅក្នុងខេត្តចំនួន៤ រួមមាន កំពង់ចាម ព្រះវិហារ ស្ទឹងត្រែង និងខេត្តរតនគិរី ចាប់ពីថ្ងៃទី១៦-២០ ខែកុម្ភៈ ឆ្នាំ២០២៥។

លោក តូច ប៊ុនហួរ បានឱ្យដឹងថា តាមការវាយតម្លៃបឋម ការប្រមូលផលស្វាយចន្ទីនៅក្នុងអំឡុងខែកុម្ភៈ នេះ មានចំនួនតិចជាងឆ្នាំកន្លងមក ដោយសារមកពីអាកាសធាតុត្រជាក់អូសបន្លាយពេលយូរ។ លោកបន្តថា តាមការវាយតម្លៃគ្រាប់ស្វាយចន្ទីឆ្នាំនេះ មានគុណភាពល្អ គ្រាប់ធំ សាច់ណែនល្អ ទិន្នផលស្វាយចន្ទីឆ្នាំនេះ អាចកើនឡើងខ្ពស់ជាងឆ្នាំ២០២៤។

លោកបានបន្តទៀតថា ស្ថានភាពទីផ្សារ និងតម្លៃនៅដើមរដូវឆ្នាំនេះ គ្រាប់ស្វាយចន្ទីមានតម្លៃខ្ពស់ ដូចឆ្នាំ២០២០ ពោលមានតម្លៃចន្លោះពី៦០០០ ទៅ៦៦០០រៀល នៅក្នុងមួយគីឡូក្រាម។

At the start of the year, cashew nuts were priced between 6,000 and 6,600 riels per kilogram

Touch Bun Hour, the Secretary of State at the Ministry of Agriculture, Forestry and Fisheries, stated that the market situation and pricing for cashew nuts at the start of the season mirror those of 2020, with prices consistently falling within the same range.

He made these remarks while leading a working group to inspect the status of crop production, particularly focusing on industrial crops and cashew nuts, as well as evaluating warehouse locations, market conditions, and pricing in four provinces: Kampong Cham, Preah Vihear, Stung Treng, and Ratanakkiri, during the period from February 16 to February 20, 2025.

Touch Bun Hour mentioned that preliminary estimates indicate a lower cashew harvest in February compared to last year, attributed to the prolonged cold weather. However, he highlighted that the quality of this year's cashew nuts is excellent, with larger nuts and better meat, suggesting that the yield could surpass that of 2024.

Additionally, he reiterated that the market prices at the beginning of the season remain as high as in 2020, falling within the 6,000 to 6,600 riel range per kilogram.

# អភិបាលខេត្តកំពង់ធំ បន្តជំរុញគោលនយោបាយស្វាយចន្ទី ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ

CNC News, February 24, 2025

កំពង់ធំ៖ អភិបាលខេត្តកំពង់ធំ លោក នួន ផារ័ត្ន បានលើកឡើងថា ខេត្តកំពង់ធំ ជាខេត្តដែលមានសក្តានុពលលើវិស័យកសិកម្ម ជាពិសេសដំណាំស្វាយចន្ទី។ ដំណាំស្វាយចន្ទីនេះ គឺជាគោលនយោបាយដ៏សំខាន់មួយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា ក្នុងការពង្រឹង និងពង្រីកវិស័យកសិកម្មរបស់កម្ពុជា សម្រាប់ជួយទ្រទ្រង់សេដ្ឋកិច្ចជាតិ ហើយគោលនយោបាយនេះ ត្រូវបានបន្តជំរុញទៅមុខជាប់ជាប្រចាំ សំដៅលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ»។

លោក នួន ផារ័ត្ន បានលើកឡើងដូចនេះក្នុងពិធីចុះកិច្ចសន្យាទិញលក់គ្រាប់ស្វាយចន្ទីសើម រវាងក្រុម ហ៊ុនមីរ៉ាត់ អាហ្គ្រី ថេក ឯ.ក (Mirarth) និងសហគមន៍កសិកម្មក្នុងខេត្តកំពង់ធំ នៅព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៥។

លោក នួន ផារ័ត្ន បានលើកឡើងថា ការងារកសិកម្មនេះ សម្រាប់ខេត្តកំពង់ធំមានប្រជាពលរដ្ឋ ប្រមាណជាង ៧៣% ធ្វើកសិកម្ម។ ថ្មីៗនេះ សម្តេចមហាបវរធិបតី បានអញ្ជើញមកកាន់ខេត្តកំពង់ធំ ដោយផ្ទាល់នៅសហគមន៍ស្វាយចន្ទីចំនួនពីរលើករួចមកហើយ ដើម្បីពិនិត្យមើលសហគមន៍ទំនើប ព្រមទាំងបានដាក់ចេញនូវគោលនយោបាយមួយដែលត្រឹមត្រូវចាប់តាំងពីការដាំដុះ រហូតដល់ការនាំចេញ ធ្វើយ៉ាងណាជំរុញកម្ពុជាក្លាយជាប្រទេសនាំចេញមុខគេក្នុងវិស័យស្វាយចន្ទី។






# KAMPONG THOM PROVINCIAL GOVERNOR ADVOCATES FOR CASHEW POLICY TO ENHANCE LIVELIHOODS

Kampong Thom provincial Governor Mr. Nuon Pharath highlighted the region's agricultural potential, particularly in cashew production. He emphasized that the cultivation of cashews is a key initiative promoted by Prime Minister Hun Manet, aimed at bolstering and expanding Cambodia's agricultural sector to support the national economy. This initiative is consistently advanced to improve the livelihoods of local communities.

Governor Pharath shared these insights during a contract signing ceremony for the sale of wet cashews, which took place on February 24, 2025, involving Mirarth Agri Tech Co., Ltd. and local agricultural communities.

He noted that over 73% of Kampong Thom's population is engaged in agriculture. Recently, the Prime Minister made two visits to inspect the cashew community, focusing on establishing effective policies for the entire supply chain, from cultivation to export, with the goal of positioning Cambodia as a leading cashew nut exporter.

# សមាគមស្វាយចន្ទីកម្ពុជា សាទរការជំរុញឱ្យអ្នកមានធនធានវិនិយោគលើការកែច្នៃគ្រាប់ស្វាយចន្ទី

# CAC ENCOURAGES TYCOONS TO INVEST IN CASHEW PROCESSING

BC News ១៧ មីនា ២០២៥

សមាគមស្វាយចន្ទីកម្ពុជា បានបង្ហាញការសាទរ និងគាំទ្ររាល់ការជំរុញឱ្យអ្នកមានធនធានវិនិយោគលើការកែច្នៃគ្រាប់ស្វាយចន្ទី ព្រោះបានរួមចំណែកជួយអភិវឌ្ឍន៍វិស័យចន្ទីកម្ពុជាឱ្យកាន់តែខ្លាំងឡើងថែមមួយកម្រិតទៀត។ ការបង្ហាញការគាំទ្របែបនេះ ធ្វើឡើងក្រោយពេលសម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាបានស្នើសមាជិកនៃ សមាគមឧកញ៉ាជួយវិនិយោគលើការកែច្នៃគ្រាប់ស្វាយចន្ទីកម្ពុជា។

ថ្លែងប្រាប់សាព័ត៌មាន BC News នៅព្រឹកថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២៥ ប្រធានសមាគមស្វាយចន្ទីកម្ពុជា អួន ស៊ីឡុត បានលើកឡើងថា ជារឿងមួយដែលល្អដែលសម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាកម្ពុជា លើកទឹកចិត្តឱ្យសមាជិកនៃសមាគមឧកញ៉ា គិតគូរឡើងវិញ ក្នុងការអភិវឌ្ឍន៍ និងវិនិយោគលើការកែច្នៃស្វាយចន្ទី ខណៈបច្ចុប្បន្នការកែឆ្នៃនៅកម្ពុជាហាក់តិចតួចនៅឡើយ។

លោកបន្ថែមថា ត្បិតថា កម្ពុជា ជាប្រទេសដែលផលិតចន្ទីធំជាងគេទី២ លើពិភពលោក ក៏ពិតមែនការនាំចេញគ្រាប់ស្វាយចន្ទីបានជិត ៨០ ម៉ឺនតោនទៅកាន់ប្រទេសវៀតណាម កាលពីឆ្នាំ២០២៤កន្លងទៅ។ ជាមួយគ្នានេះ ការកែឆ្នៃស្វាយចន្ទីនៅក្នុងស្រុកនៅតែមានកម្រិត ហេតុនេះ លោក អួន ស៊ីឡុត អះអាងថា ការជំរុញការកែច្នៃស្វាយចន្ទីនៅក្នុងស្រុកឱ្យបានច្រើន គឺជារឿងដ៏ល្អ និងត្រឹមត្រូវ ព្រោះជួយបង្កើនតម្លៃបន្ថែមដល់កសិករ ជួយបង្កើនសេដ្ឋកិច្ចសហគមន៍ ព្រមទាំងបានចូលរួមកាត់បន្ថយការចំណាកស្រុករបស់ប្រជាពលរដ្ឋថែមទៀត។

Phnom Penh – The Cashew Nut Association of Cambodia (CAC) has articulated its support for initiatives aimed at attracting investment in the cashew processing sector. This endorsement follows a request from Samdech Techo Hun Sen, President of the Senate, who urged members of the Oknha (Duke) Association to consider investing in the processing of Cambodian cashew nuts.

In a statement to BC News on March 17, 2025, Silot Uon, Chairman of the CAC, commended Samdech Techo Hun Sen for encouraging the Oknha (Duke) Association to reassess opportunities for investment in local cashew processing, which remains limited at present.

Despite Cambodia's status as the world's second-largest producer of cashews, the export of approximately 800,000 tons of cashew nuts to Vietnam in 2024 underscores the challenges facing local processing capabilities. Silot posits that enhancing local cashew processing is essential, as it not only increases the value for farmers but also bolsters the community economy and mitigates migration.

# កម្ពុជាបង្កើតមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពផលិតផល ដើម្បីជួយពន្លឿនការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ

# CAMBODIA ESTABLISHED QUALITY CONTROL LAB TO ENHANCE ITS EXPORTS

Cambonomist News

មជ្ឈមណ្ឌលកែច្នៃអាហារ និងនវានុវត្តន៍ និងមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាព ឡាប្យូស្សែត (LABIOCERT) ដំបូងគេនៅកម្ពុជារបស់ក្រុមហ៊ុន PPM-Confirel បានសម្ពោធដាក់ឱ្យដំណើការជាផ្លូវការហើយ ដើម្បីផ្តល់ទំនុកចិត្ត និងសុវត្ថិភាពដល់អតិថិជនសំដៅចូលរួមចំណែកជួយលើកកម្ពស់ការកែច្នៃ និងពង្រឹងគុណភាពម្ហូបអាហារ និងផលិតផលខ្មែរ។ សមិទ្ធផលនេះ ក៏ជាផ្នែកមួយជួយពន្លឿនប្រសិទ្ធភាពនៃការនាំចេញផលិតផលខ្មែរទៅកាន់ទីផ្សារអន្តរជាតិផងដែរ តាមរយៈការជួយកាត់បន្ថយពេលវេលា និងថវិកាក្នុងការប្រើប្រាស់សេវាត្រួតពិនិត្យគុណភាពទំនិញនៅក្រៅប្រទេស។

The inauguration of PPM-Confirel's Food Processing and Innovation Center, alongside LABIOCERT Quality Control Laboratory—a groundbreaking facility in Cambodia—marks a significant milestone for the community. This center is dedicated to fostering customer confidence and enhancing the safety of food products, all while improving the quality of Khmer goods that we cherish.

We recognize the challenges faced by local producers in accessing international markets. We hope to ease some of those burdens with this new facility by reducing the time and costs associated with quality control services abroad. Our goal is to empower Cambodian businesses and help them thrive on the global stage.

# អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា៖ ការលើកទឹកចិត្តផ្នែកគយនឹងជំរុញវិស័យស្វាយចន្ទី

**កាសែតខ្មែរថាមស៍ ម៉ម គន្ធា ៦ មីនា ២០២៥**

កាលពីថ្ងៃអង្គារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានរៀបចំសិក្ខាសាលាស្ដីពីការលើកទឹកចិត្តផ្នែក គយរបស់រដ្ឋាភិបាលសម្រាប់ការកែច្នៃ ការនាំចេញ និងនាំចូលស្វាយចន្ទី។

សិក្ខាសាលាស្ដីពី «ការលើកទឹកចិត្តផ្នែកគយដល់សមាគមស្វាយចន្ទីកម្ពុជា» បានប្រព្រឹត្តិទៅក្រោមអធិបតីលោក ប៊ុន ជីវ ប្រធាននាយកដ្ឋានរបបគយ នៅរាជធានីភ្នំពេញ។

លោក អួន ស៊ីឡុត ប្រធានសមាគមស្វាយចន្ទីកម្ពុជា លោក ស៊ុយ កុកធាន អនុប្រធានសមាគមស្វាយចន្ទីកម្ពុជា រួមជាមួយតំណាងសហគមន៍ អ្នកដាំស្វាយចន្ទី អ្នកកែច្នៃ និងអ្នកនាំចេញក៏បានចូលរួមក្នុងសិក្ខាសាលានេះ ផងដែរ។

ដោយគូសបញ្ជាក់ពីសារៈសំខាន់នៃសិក្ខាសាលា លោក ប៊ុន ជីវ បានមានប្រសាសន៍ថា សិក្ខាសាលានេះរៀបចំឡើងស្របតាមគោលនយោបាយជាតិស្ដីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧។

លោកបានបន្ថែមថា៖ «គោលនយោបាយនេះត្រូវបានរៀបចំឡើងដើម្បីចូលរួមជំរុញនិងគាំទ្រការពង្រឹងភាពប្រកួតប្រជែង និងការបង្កើនសមត្ថភាពផលិតកម្មក្នុងវិស័យ ស្វាយចន្ទី ហើយជាមួយគ្នានេះ ក៏មានគោលបំណងស្វែងយល់ពីបញ្ហាប្រឈមសំខាន់ៗនៃវិស័យនេះ ដើម្បីជាធាតុចូលសម្រាប់រៀបចំដាក់ចេញនូវយន្តការលើកទឹកចិត្តនិងគាំទ្របន្ថែម»។




## CUSTOMS INCENTIVES TO BOOST CASHEW SECTOR, GDCE SAYS

The General Department of Customs and Excise of Cambodia (GDCE) Tuesday conducted a workshop on government customs incentives for the processing, exporting, and importing of the cashew sub-sector.

The workshop on 'Customs Incentives to Cashew Nut Industry' was chaired by Bun Chiv, Director of the Customs Department of the General Department of Customs and Excise of Cambodia, in Phnom Penh.

Uon Silot, President of the Cashew Nut Association of Cambodia (CAC), Suy Kokthhean, Vice President of CAC along with representatives from the community, cashew growers, processors, and exporters took part in the workshop.

Underscoring the significance of the workshop, Chin said it aligns with the National Policy on Cashews for 2022-2027.

"This policy is designed to actively promote customs incentives that will enhance competitiveness and build capacity within the cashew sector. The workshop's objective was clear to identify the key challenges faced by this sector and to formulate additional incentives and support mechanisms that will drive progress," he said.



# កសិកម្មទ្រទ្រង់ដល់បរិស្ថាន

ការធ្វើកសិកម្មល្អគឺធ្វើយ៉ាងណាដើម្បីបង្កើនប្រាក់ចំណេញ ប៉ុន្តែត្រូវធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធកសិកម្ម អេកូឡូស៊ី ព្រមទាំងធ្វើឱ្យផលិតកម្មដំណាំនិងបសុសត្វមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុនិង តម្លៃលើទីផ្សា។ គោលដៅកសិកម្មល្អគឺទ្រទ្រង់បរិស្ថាន បង្កើនគុនភាពដីកសិកម្ម ក្នុងរយៈពេលវែង ដោយផ្លាស់ប្តូរកសិកម្មតាមទម្លាប់ ដើម្បីឆ្ពោះទៅរកកសិកម្មមួយដែលសមស្របដោយផ្តល់ទាំងផលល្អ និង គុណភាពបរិស្ថានល្អ។

កសិកម្មល្អ ជាកសិកម្មដែលប្រើវិធីសាស្ត្រគ្រប់គ្រងដោយប្រព័ន្ធអេកូឡូស៊ី សម្រាប់កែលម្អនិងរក្សាឱ្យមានចេរភាពនៃផលិតភាពដំណាំ បង្កើនផលចំណេញនិងសន្តិសុខស្បៀង ដោយមានការថែរក្សា និងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានធនធានធម្មជាតិនិងបរិស្ថាន កសិកម្មល្អផ្សារភ្ជាប់ដោយគោលការណ៍ សំខាន់៣គឺ

១ កាត់បន្ថយការភ្ជួរដីសម្រាប់ដំណាំឈើហូបផ្លែ

២ ធ្វើពិពិធកម្មប្រភេទដំណាំ តាមរយៈការដាំដំណាំឆ្លាស់ ឬដំណាំចម្រុះ

៣ ដីត្រូវមានគម្របជាអចិន្រ្តៃយ៍តាមរយៈការដាំដំណាំគម្របដី

# ហេតុអ្វីគួរដាំដំណាំ ឆ្លាស់ ឬដំណាំចម្រុះ ?




- ជួយជាគម្របដី ការពារសំណឹក
- ជួយបង្កើនជីវៈចម្រុះ
- កាត់បន្ថយការបាត់បង់អាសូតពីក្នុងដី
- បង្កើនគុណភាពដី

## ដំណាំគម្របដី

ការដាំដំណាំគម្របដី ជាកត្តាចម្បងនិងសំខាន់សម្រាប់បំពេញតម្រូវការនៃសារធាតុចិញ្ចឹមសម្រាប់ដំណាំ។ ការដាំដំណាំគម្របដី ផ្តល់ការការពាររូបសាស្រ្តដល់ដីពីយន្តការផ្សេងៗដែលបង្ករឱ្យមានការសឹករិចរឹល ដីជាតិដីដោយការហូរច្រោះ ការការពារដីពីការប៉ះផ្ទាល់ពីពន្លឺព្រះអាទិត្យ ។ល។ ដំណាំគ្របដី ដែលអាចរកបាននៅក្នុងប្រទេសកម្ពុជាមានដូចជា សណ្តែកអាចម៍កណ្តុរ សណ្តែកអង្រែ សណ្តែកអង្គុយ សណ្តែកដីព្រៃ ស្មៅគោក ចង្រ្កង់ស្វា ចង្រ្កង់ស្វាស្លឹកតូច ស្មៅជើងក្រាស។ រុក្ខជាតិមួយចំនួនមាននៅ បរទេសដូចជា ស្ទីឡូ សេនត្រូ ស៊ិគុម មីម៉ូសា ម៉ាឡាតូ មុំបាសា ប៉ាស្ប៉ាលូម ។

នៅក្នុងរងឈើហូបផ្លែជាពិសេស ស្វាយចន្ទីគួរដាំ ដំណាំគម្របដី ដូចជា ស្ទីឡូ សណ្តែកអង្រែ សណ្តែកអង្គុយ សណ្តែកដីព្រៃ។ អត្ថប្រយោជន៍ សណ្តែកព្រៃ ផលិតជីវម៉ាស់ទាបចំពោះដីសឹករិករឹលខ្លាំង គឺតិចជាង៣តោនក្នុងមួយហិកតា។ ផ្តល់អត្ថប្រយោជន៍ច្រើនទៅឱ្យដី វាទប់ស្កាត់ការហូរច្រោះទៅតាម ប្រព័ន្ធឫសរបស់វា។ សណ្តែកព្រៃអាចផលិតអាស៊ូតបានច្រើនជាង ១៥០គីឡូក្រាមក្នុងមួយហិកតា។ ដាំវា អាចបន្ថយការប្រើប្រាស់ជីអាសូត និងប៉ូតាស្យូម ល្អសម្រាប់ដីល្បាយខ្សាច់។

ឯកសារយោង ស្មាតអាក្រូ បកប្រែទៅជាភាសាអង់គ្លេសដោយ អួន ស៊ីឡុត







# ENVIRONMEN-TAL-FRIENDLY FARMING

Good farming practices can increase profits, enhance the ecological agricultural system, and make crop and livestock production more resilient to climate change and market fluctuations. Sustainable agriculture aims to improve the long-term quality of agricultural land by adopting appropriate farming practices that yield positive results while promoting environmental health.

1. MINIMIZE OR ELIMINATE LAND DISTURBANCE, SUCH AS THROUGH NO-TILLAGE FARMING.
2. DIVERSIFY CROP TYPES BY CULTIVATING ALTERNATIVE OR MIXED CROPS.
3. ENSURE THE LAND IS PERMANENTLY COVERED BY PLANTING COVER CROPS

# WHY SHOULD WE PLANT MIXED CROPS?



- HELPS PREVENT SOIL EROSION
- INCREASES BIODIVERSITY.
- REDUCES NITROGEN LOSS FROM THE SOIL
- IMPROVES LAND QUALITY.

## Cover crops

**Cover crop cultivation is crucial for meeting crops' nutrient needs. Cover crops protect the soil from erosion, contamination, and various physical mechanisms. They also shield the soil from direct sunlight. Some cover crops found in Cambodia are Ricebean, Pigeon peas, Cow-pea, Repen, Sesbinia, Sunn Hemp, Rattlepod, and Finger Millet. The exotic cover crops are Stylo, Centro, Sorghum, Pearl Millet, Mulato II, Mombasa Guinea, and Paspalum Atratum.**

**Fruit trees, particularly cashew trees, should be planted alongside Stylo, pigeon peas, cow-peas, and Repens. Repens, for example, offers several benefits: it produces less than 3 tons of biomass per hectare, improves soil health, and helps prevent erosion with its root system. Additionally, Repens can fix over 150 kg of nitrogen per hectare, which can reduce the need for nitrogen and potassium fertilizers. Repens is good for sandy soils.**

Source: Smart Agro—Translated to English by Silot Uon

# តើអ្នកយកមួយណា រវាងធ្វើកសិកម្មរត់តាមទីផ្សារ ឬធ្វើកសិកម្មដោយមានកិច្ចសន្យាច្បាស់លាស់ ?

កសិករខ្មែរយើង ភាគច្រើនចង់បានទីផ្សាតម្លៃច្បាស់លាស់ តែពេលអនុវត្ត ពួកគាត់សុខចិត្តរត់ តាមទីផ្សារ។ ដោយហេតុថា នៅពេលចុះកិច្ចសន្យា អ្នកទិញមិនអាចឲ្យតម្លៃស្មើឬលើសតម្លៃទីផ្សារបាន ឡើយ តែគេឲ្យក្រោមតម្លៃទីផ្សារ។
តើអ្នកលក់ទទួលបានប្រយោជន៍អ្វី បើអ្នកទិញក្នុងកិច្ចសន្យា កំណត់របៀបហ្នឹង?
ប្រយោជន៍ទទួលបានគឺ:

១. បច្ចេកទេសត្រឹមត្រូវ ដែលនាំឲ្យកើនទិន្នផល ខណ:ពេលដែលចំណាយក្នុងការផលិតអាចនៅដដែល ឬថយចុះ។

២. ទទួលបានការផ្គត់ផ្គង់ជីនិងថ្នាំដែលមានគុណភាព និងតម្លៃសមរម្យ។

៣. កសិករ មួយក្រុមចងក្រងជាសហគមន៍មួយមានដីសរុប ៥០០ហិកតា ចុះកិច្ចសន្យាផ្គត់ផ្គង់ដំឡូងមី ស្ងួតឲ្យក្រុមហ៊ុននាំចេញមួយ។ ថ្លៃដើមត្រូវចាយ ១៥០០ដុល្លា/ហត។ ទិន្នផលមធ្យមដំឡូងក្រៀមទទួលបាន១៥តោន។ ក្នុងតម្លៃបច្ចុប្បន្ន ពួកគាត់លក់បានតែ ១៥០ដុល្លា/តោន ដូច្នេះចំណូលដុលរបស់ គាត់គឺ ២២៥០ដុល្លា/ហត។ គាត់ក៏នៅអាចចំណេញបាន ៧៥០ដុល្លា/ហត។ ទន្ទឹមនឹងនេះ កសិករមួយក្រុមទៀត ដាំតាមចំណង់រៀងៗខ្លួន គាត់ម្នាក់ៗចំណាយអាចចន្លោះពី ១២៥០ដល់១៧៥០ដុល្លា/ហត។ ទិន្នផលដំឡូងក្រៀម អាចបានជាមធ្យម ១០ទៅ១២តោន/ហត។ ក្នុងតម្លៃ១៥០ដុល្លា/តោនដូចគ្នា ក្រុមទី២នេះសរុបចំណូលបានតែ ១៥០០ទៅ១៨០០ដុល្លា/ហត។ ដូច្នេះក្នុងក្រុមទី២ អាចមានត្រឹមតែអ្នករួចដើម ឬចំណេញបានត្រឹម៥៥០ដុល្លាខ្ពស់បំផុត។ ពួកគាត់ត្រូវការតម្លៃ ចាប់ពី២០០ដុល្លា/តោនឡើង ទើបពួកគាត់មានឱកាសចំណេញសល់ល្មមទូទាត់ការ ប្រាក់និងផ្គត់ផ្គង់គ្រួសារ។

ក្នុងការប្រៀបធៀបរវាងក្រុមទាំងពីរ ឃើញថាក្រុមទី១ ដឹងតែបានចំណេញដោយមិនចំណុះឲ្យតម្លៃទីផ្សា ប្រែប្រួល។ ផ្ទុយមកវិញ ក្រុមទី២ ហេងស៊យទៅតាមហាងឆេងតម្លៃទីផ្សាឡើងចុះ។

គួរឲ្យស្តាយ តម្លៃទីផ្សារអន្តរជាតិឡើងចុះអាស្រ័យលើការប្រកួតប្រជែងក្នុងផ្នែកផ្គត់ផ្គង់និងតម្រូវការ។ បើអ្នកទិញកាន់តែច្រើន ពិតណាស់តម្លៃនឹងឡើងក្នុងរយ:ពេលខ្លី។ ផ្ទុយមកវិញនៅពេលអ្នកផ្គត់ផ្គង់កើនឡើងដោយសារតែអ្នកទិញនៅដដែលឬថយចុះ តម្លៃប្រាកដជាធ្លាក់ក្នុងរយ:ពេលដ៏យូរ។ ជាក់ស្តែងតម្លៃ ឡើងខ្ពស់អស់ហើយបានត្រឹម៣ឆ្នាំ។ តែតម្លៃអាចធ្លាក់ចុះទាបរហូតដល់៨ទៅ៩ឆ្នាំ។ ឧ. ឆ្នាំ ២០០៨ដល់២០១១ តម្លៃដំឡូងស្រស់ឡើងខ្ពស់ដល់ ៤០០រៀលទៅ៦០០រៀល/គក្រ។ ចាប់ពី២០១២ មកដល់២០១៩ តម្លៃចុះទាបរហូត។ ឆ្នាំ២០២០ដល់២០២៣ តម្លៃដំឡូងក៏ហក់ឡើងជាថ្មី។ ២០២៤ ចាប់ផ្តើមចុះវិញទៀត។ មិនដឹងថាវាសនាដំឡូងមីនឹងបានដូចមុនឬក៏យ៉ាប់ជាងមុនទេ។ ទោះវាសនាដំឡូងមីបែបណាក៏ដោយ សូមកសិករទាំងឡាយចាំថា យើងមិនអាចបញ្ជាកត្តាខាងក្រៅដែលមិនស្ថិតក្នុងកណ្តាប់ដៃរបស់យើងទេ តែយើងអាចបញ្ជាបានតែអ្វីដែលស្ថិតក្នុងការគ្រប់គ្រងរបស់យើងតែប៉ុណ្ណោះ។ អ្វីដែលអាចធ្វើបានគឺ
១. រកអ្នកទិញឲ្យហើយ មុននឹងដាំដុះ។
២. “បង្កើនទិន្នផល តែកាត់បន្ថយចំណាយ”។
៣. គោរពកិច្ចសន្យាដែលខ្លួនបានសរសេរ។

ក្រៅពីតម្លៃមិនដូចប្រាថ្នា អាកាសធាតុក៏មិនដូចប្រាថ្នារបស់កសិករដែរ។ ដូច្នេះក្នុងបរិបទប្រឈមដ៏ស្មុគស្មាញ ដែលមានកត្តាប្រឈមធំពីរ (ទីផ្សារនិងអាកាសធាតុប្រែប្រួល) កសិករតែអង្គឯងពិតជាកណ្តោចកណ្តែងណាស់។ តើបញ្ហានឹងដោះស្រាយបានដូចម្តេចទៅ? តើអ្នកណាខ្លះត្រូវចូលរួមដោះស្រាយ? បើមិនរួមគ្នាដោះស្រាយ តើវិបត្តិនឹងវិវត្តន៍ទៅបែបណា?

# CAC FINANCIAL & CONTRIBUTORS

សមាគមស្វាយចន្ទីកម្ពុជា ពុំមានការគាំទ្រហិរញ្ញវត្ថុពីស្ថាប័នអង្គការជាតិឬអន្តរជាតិមួយណាទេ។ រាល់សកម្មភាពដំណើរការរបស់ សសក កើតឡើងពីការរៃអង្គាសវិភាគទានបន្តិចបន្តួចប្រចាំឆ្នាំ ២០២៤ ពីសមាជិកសមាជិកា ជាកសិករ និង សហគ្រាស កែច្នៃស្វាយចន្ទី ដូចមានរាយនាមខាងក្រោម៖

The Cashew Nut Association of Cambodia is the most significant non-profit entity in Cambodia dedicated to working with farmers, traders, processors, and exporters. Despite limited financial resources due to the small membership fee, we are committed to our cause. CAC does not receive financial support from NGOs or international aid. However, it receives a minuscule membership fee.

១៩៦. វីណាវង់ ខេត្តសៀមរាប
១៩៧. សាន់ ផៃ
១៩៨.លឹម ចិន្តាវុធ មណ្ឌលគីរី
១៩៩. អ៊ីន ហោលាង ក្រចេះ
២០០. ស្រួ យីណា  កំពង់ចាម
២០១. សុខ មុន្នី  រតនគិរី
២០២. ម៉ប់សំណាង កំពង់ធំ
២០៣. ឡៅ ផាន់នី កំពង់ចាម
២០៤.ហាក់ គឹមថុង  ឧត្តរមានជ័យ
២០៥. ឈាន់ ភារដ្ឋ កំពង់ធំ
២០៦. ថន និត្តេបូ ទឹកផុស កំពង់ឆ្នាំង
២០៧. ទូន យា កំពង់ធំ
២០៨. មន នី ឃុំព្រះដំរី ស្រុកស្ទោង ខេត្តកំពង់ធំ
២០៩. ឌុល ចិន្តា ទំរីង កំពង់ធំ
២១០.លួត សីលា កំពង់ស្វាយ កំពង់ធំ
២១១. សហគ្រាស ពាកូអេកូ
២១២. មុំ សុខផៃ ( ប៉ៃលិន )
២១៣. ញាណ ប៊ុន្នី
២១៤. ហេង ធារិទ្ធ រតនគិរី
២១៥. រឿន សូនី កំពង់ធំ
២១៦. សែម មុន្នីសោភ័ណ
២១៧. អាង សៀងប៊ុន
២១៨. អិត ផល្គុន វាលដេញ ស្ទឹងត្រែង
២១៩. សន ស្រស់ ស្រុកសូទ្រនិគម ខេត្តសៀមរាប
២២០.ដេប៉ូ រិត តុលា នៅ កំពប់បិល ស្រុកសន្ទុក កំពង់ធំ
២២១. កែវ វិចិត្រ កំពង់ធំ
២២២. អៀន គ្រីន កំពង់ធំ
២២៣. ទូន យា កំពង់ចាម
២២៤. ឌុយ តុងស៊ីល កំពង់ធំ
២២៥. ងី ប៊ុនលី  កំពង់ធំ
២២៦. តុប ស៊ាងហៃ ត្បូងឃ្មុំ
២២៧. ងួន គួយ  ស្ទឹងត្រែង
២២៨. សេង លីហ៊ត ក្រចេះ
២២៩. សាយ ពៅដាវីន ស្រុកសន្ទុក ខេត្តកំពង់ធំ
២៣០. ញ៉ូវ គីមសួ ក្រចេះ
២៣១. ប៉ែន ឧត្តម ខេត្តឧត្តរមានជ័យ
២៣២. ហូ សៅនី
២៣៣. ដាម លាស់ ព្រះវិហារ
២៣៤. លី គឹមស៊ុយ សន្ទុក កំពង់ធំ
២៣៥. ហៃ ហ៊ត នៅឃុំស្រើង ស្រុកប្រាសាទសំបូរ
២៣៦. តេង ចំរ៉ុង កំពង់ធំ
២៣៧. អ៊ុន គឹមអ៊ី កំពង់ធំ
២៣៨. មីត រ៉ានី  កំពង់ធំ
២៣៩. លឹម ប៉ូ កំពង់ធំ
២៤០.Him Panha ត្បូងឃ្មុំ
២៤១. ហាក់ សុជាតិ ស្វាយលើ សៀមរាប
២៤២. ជា កល្យាណ សិប្បកម្មផៃយ៉ាណា កំពង់ឆ្នាំង
២៤៣. ញ៉ឹប វុទ្ធី  កំពង់ចាម
២៤៤. ញាណ ប៊ុន្នី ខេត្តក្រចេះ
២៤៥. ឡុង ស៊ីណាក់ កំពង់ធំ
២៤៦. អេង ម៉េងស្រួយ  ខេត្តកំពង់ចាម
២៤៧. ជា ប៊ុនឡូ ឃុំរណសិរ្ស ស្រុកសង្គមថ្មី ខេត្ត ព្រះវិហារ
២៤៨. ហៅ ចិន្តារី ខេត្តកំពង់ចាម
២៤៩. សាយ ពៅដាវីន កំពង់ធំ
២៥០. កុយ វួន សង្គមថ្មី ខេត្តព្រះវិហារ
២៥១. អុំ សុខារ៉ានិន្ទ ភូមិចុងព្រៃ ឃុំកំពង់ស្វាយ ខេត្តកំពង់ធំ
២៥២. ខុន សុខខន ខេត្តកំពង់ចាម
២៥៣. ស៊ឹម តាំងឡូត ខេត្តកំពង់ចាម ចំការលើ
២៥៤. អោង មួយលាង ត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
២៥៥. សហគ្រាស 3CORsEco
២៥៦. ហ៊ី ម៉េងឡៃ ខេត្តកំពង់ធំ សណ្ដាន់ ទំរីង
២៥៧. ឈឿន ងួនហេង សន្ទុក កំពង់ធំ
២៥៨. ឆោម រដ្ឋា ខេត្តក្រចេះ
២៥៩. រស់ ចន្ទីខេត្តកំពង់ចាម
២៦០. ហួយ សុផាត  កំពង់ធំ
២៦១. ប៉េង សូរិយា ក្រចេះ
២៦២. ហ៊ា ស៊ុយម៉េង
២៦៣. ធី បារាំង  ក្រចេះ
២៦៤. គង់សំណាង ក្រចេះ
២៦៥. Horn Chhaily
២៦៦. អិត ផល្គុន ស្ទឹងត្រែង
២៦៧. អ៊ីន ភារី ខេត្តកំពង់ធំ
២៦៨. ឈ្មោង រិទ្ធិ ក្រចេះ
២៦៩. ឈីន ចាន់សេង ក្រចេះ
២៧០. និន ដារ៉ា ស្ទឹងត្រែង
២៧១. សហគមន៍កសិកម្មកៅស៊ូគ្រួសារគោកដូងអង្គរជុំ ខេត្តសៀមរាប
២៧២. ទូត វុត្ថា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
២៧៣. ខន ខា សៀមរាប
២៧៤. ស៊ឹម ស៊ីដែន ខេត្តរតនគិរី
២៧៥. អៀន គ្រីន
២៧៦. ង៉ែត រស់ កំពង់ធំ
២៧៧. ងួន គឹមសុង ខេត្តកំពង់ចាម
២៧៨. ផន សូភ័ណ្ឌ ភូមិស្នោ ឃុំត្រពាំង

# ប្រវត្តិសមាគមស្វាយចន្ទីកម្ពុជា

# CAC BACKGROUND

សមាគមស្វាយចន្ទីកម្ពុជា (សសក) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៩ ក្រោមច្បាប់នៃប្រទេសកម្ពុជា។ សសក ជាស្ថាប័នក្រៅរដ្ឋាភិបាល ធ្វើការទាក់ទងនឹងខ្សែច្រវាក់ផលិតកម្ម ស្វាយចន្ទី។ គោលដៅសំខាន់គឺពង្រឹងភាពប្រកួតប្រជែង និងអភិវឌ្ឍវិស័យស្វាយចន្ទីក្នុងសហគមន៍កសិកម្មនិងអ្នកកែច្នៃ។ សសក មានសមាជិក ១៩ ៧២១ (ក្នុងចំណោម ២៥ ០០០) គ្រួសារ ៤៧ សហគមន៍កសិកម្ម លើផ្ទៃដីចំនួន ៣៧០ ០០០ហិកតា និងមានសមាជិកជាឈ្មួញ និងសហគ្រាសធុនតូចនិងមធ្យមចំនួន ៤៦ (ក្នុងចំណោម ៥២)។ សមាគមស្វាយចន្ទីកម្ពុជា ជាស្ថាប័ន មិនស្វែងរកប្រាក់ចំណេញ មិនចំណុះឱ្យស្ថាប័នក្រៅរដ្ឋាភិបាលណាមួយ។ សសក ធ្វើការសហការជាមួយសមាគមក្រៅរដ្ឋាភិបាលចំនួន៤ គឺសមាគមត្រចៀកកាំខ្មែរ សមាគមកសិករដំឡូងមីខ្មែរ សមាគមសហគ្រិនកសិកម្មកម្ពុជា។

The Cashew Nut Association of Cambodia (CAC) was set up under Cambodia's regulations in 2009. It is a non-governmental body along the entire cashew value chain. Its objective is to strengthen the competitiveness of Cambodia's cashew sectors and the development of Cambodian cooperative societies and cashew producers. CAC has 19,721 (out of 25,000) members (Cashew farmers), 47 Agricultural Co-operatives in a total of 370,000 hectares of cashew farms, some traders, and 46 (out of 52) small processing companies. CAC is a non-profit and non-governmental entity and not any subsidiary of any institution. CAC has also worked with the Khmer Swiftlet Association (KSA), the Khmer Farmer Cassava Association (KFCA), and the Association of Cambodia Agripreneurs (ACA).

សមាគមស្វាយចន្ទីកម្ពុជា ជាស្ថាប័នមិនស្វែងរកប្រាក់ចំណេញ។
Cashew nut Association of Cambodia is a non-profit entity.

ព្រឹត្តិបត្រព័ត៌មាននេះមិនឆ្លុះបញ្ចាំងពីវិស័យស្វាយចន្ទីទាំងមូលរបស់កម្ពុជានោះទេ!
This Newsletter does not reflect the whole Cambodian cashew industry.

# PHOTOS GALLERY

## បណ្តុំរូបភាពសកម្មភាព សមាគមស្វាយចន្ទីកម្ពុជា និងដៃគូពាក់ព័ន្ធ


















# THANK YOU

## CONTACT US

+855 77 62 92 88

info@cac-camcashew.org
www.cac-camcashew.org

Nation Road 6, Krachab Village, Stoeng sen
Town, Kompong Thom, Cambodia.